ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ៣១/០៩ — សិប្បកម្ម ម៉ារី**

**កាលបរិច្ឆេទនៃសេចក្តីសម្រេច : ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩**

# សេចក្តីសម្រេចអាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **សេង រិទ្ធហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **សិប្បកម្ម ម៉ារី**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៣៤០ ៣៣២ ទូរសារលេខ : ០២៤ ៩៨៥ ១១៨

តំណាងភាគីនិយោជក :

១- លោកស្រី ជិន សារី ប្រធានសិប្បកម្ម ម៉ារី

២- កញ្ញា ជិន មុំ ប្រធានរដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហព័ន្ធសហជីព-សហជីពខ្មែរ ប្រចាំសិប្បកម្ម ម៉ារី**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៦៥៨ ១២៥ ទូរសារ : គ្មាន

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត :

| | |
|---|---|
| ១- លោក ម៉ម ធន | មន្ត្រីដោះស្រាយវិវាទ សហព័ន្ធសហជីពខ្មែរ |
| ២- លោក សុខ សារុំ | ប្រធានសហជីពខ្មែរ ប្រចាំសិប្បកម្ម ម៉ារី |
| ៣- លោក ណន ចិន្តា | អនុប្រធានសហជីពខ្មែរ ប្រចាំសិប្បកម្ម ម៉ារី |
| ៤- លោក ឌួង ឧត្តម | លេខាធិការសហជីពខ្មែរ ប្រចាំសិប្បកម្ម ម៉ារី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- បងប្អូនកម្មករនិយោជិតនៅតែទាមទារឱ្យសិប្បកម្មទឹកផ្លែឈើម៉ារី ផ្តល់ប្រាក់អតីតភាពការងារ ដោយហេតុថា បងប្អូនក៏ជាកម្មករដូចផ្នែកវាយណភ័ណ្ឌ តម្បាញ ដេរស្បែកជើង ដែលកម្មករទាំងនោះទទួលបាននូវអត្ថប្រយោជន៍ទាំងនេះ។ ដោយឡែកភាគីសិប្បកម្មទឹកផ្លែឈើម៉ារី មិនអាចផ្តល់តាមការទាមទារនូវប្រាក់អតីតភាពការងារជូនបងប្អូនបានឡើយ ដោយហេតុថា គ្មានច្បាប់ណាតម្រូវឱ្យសិប្បកម្មផ្តល់អត្ថប្រយោជន៍នេះ ជូនកម្មករឡើយ។

២- បងប្អូនកម្មករនិយោជិតនៅតែទាមទារ ឱ្យសិប្បកម្មទឹកផ្លែឈើម៉ារី ផ្តល់ប្រាក់ទ្រទ្រង់ជីវភាព ដោយហេតុថា បងប្អូនក៏ជាកម្មករដូចផ្នែកវាយណភ័ណ្ឌ តម្បាញ ដេរស្បែកជើង ដែលកម្មករទាំងនោះទទួលបាននូវអត្ថប្រយោជន៍ទាំងនេះ។ ដោយឡែកភាគីសិប្បកម្មទឹកផ្លែឈើម៉ារី មិនអាចផ្តល់តាមការទាមទារនូវប្រាក់ទ្រទ្រង់ជីវភាពជូនបងប្អូនបានឡើយ ដោយហេតុថា គ្មានច្បាប់ណាតម្រូវឱ្យសិប្បកម្មផ្តល់អត្ថប្រយោជន៍នេះ ជូនកម្មករឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៥៣ ក.ប/អ.ក/វ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩។

## សវនាការ និង សន្និដ្ឋាននីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ (វេលាម៉ោង ០៨:៣០នាទី ដល់ម៉ោង ១១:០០នាទី)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់សហព័ន្ធសហជីពខ្មែរ លើករណីទាមទារឱ្យក្រុមហ៊ុនកែលំអរលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ ។ បន្ទាប់មក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយ និងផ្សះផ្សាជាបន្តបន្ទាប់ និងផ្សះផ្សាចុងក្រោយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០២ ចំណុច ។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ តាមរបាយការណ៍ស្ដីពីវិវាទការងាររួមមិនសះជា លេខ ១៥៣ ក.ប/អ.ក/វ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ០៨:៣០ នាទីព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់អាជ្ញាកណ្ដាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជាទាំង ០២ ចំណុច បន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្ដុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- សេចក្ដីថ្លែងហេតុរបស់លោកស្រីប្រធានសិប្បកម្ម ម៉ារី ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ។

២- ប្រកាសលេខ ៤៦១ ឧគស.ប្រក របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦ ។

៣- បទបញ្ជាផ្ទៃក្នុងនៃសិប្បកម្ម ម៉ារី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ។

៤- កិច្ចសន្យាការងាររបស់លោក ខួង ឧត្តម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៧ ដែលមានរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៧ ដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨។

៥- បញ្ជីបញ្ជូនទំនិញ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៈ**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពខ្មែរនៃក្រុមហ៊ុនទឹកផ្លែឈើ ម៉ារី លេខ ១២៦២ ក.ប/ក.វ. ចុះថ្ងៃ ទី ០១ ខែតុលា ឆ្នាំ២០០៧។

២- កំណត់ហេតុស្តីពីការបង្កើតសហជីពខ្មែរនៃក្រុមហ៊ុនទឹកផ្លែឈើ ម៉ារី ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩

៣- បញ្ជីឈ្មោះកម្មករនិយោជិត ដែលជាសមាជិកសហជីពខ្មែរ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅសិប្បកម្មទឹកផ្លែឈើ ម៉ារី លេខ ១៩៣ ក.ប/អ.ក/វ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមនៅសិប្បកម្មទឹកផ្លែឈើម៉ារី ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៣៤ កប/អក/វក/ លកអ. ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៩ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៈ**

- សិប្បកម្មទឹកផ្លែឈើម៉ារីបានចាប់ដំណើការនៅឆ្នាំ២០០៣។ បច្ចុប្បន្ននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៥០ នាក់។
- នៅក្នុងសិប្បកម្មទឹកផ្លែឈើម៉ារី មានសហជីពតែមួយទេ គឺសហជីពខ្មែរប្រចាំសិប្បកម្ម ដែលជាភាគីដើមបណ្តឹងក្នុងសំណុំរឿងនេះ។

- ភាគីសហជីព និងនិយោជក បានបញ្ជាក់ទទួលស្គាល់ថា ក្នុងចំណោមកម្មករនិយោជិតទាំង ៥០ នាក់នេះ មានកម្មករនិយោជិតចំនួន ១៩ នាក់ ជាសមាជិកសហជីពខ្មែរ ។
- សហជីពខ្មែរ មិនមានភាពតំណាងបំផុតទេ ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើ ម៉ារី ផ្តល់ប្រាក់អតីតភាពការងារ ដោយហេតុថា កម្មករនិយោជិតធ្វើការនៅសិប្បកម្ម ក៏ដូចកម្មករនិយោជិតធ្វើការ នៅផ្នែកវាយណភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើងដែរ ហើយដែលត្រូវទទួលបានអត្ថប្រយោជន៍ដូចគ្នា**

- កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើម៉ារី ផ្តល់ប្រាក់អតីតភាពការងារជូនពួកគាត់ ដូចកម្មករនិយោជិតផ្នែកវាយណភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែរ ពីព្រោះពួកគាត់បានបំរើការងារឱ្យសិប្បកម្មនេះជាច្រើនឆ្នាំ (ពី ០៤ ឆ្នាំ ដល់ ០៧ ឆ្នាំ) មកហើយ ហើយមិនដែលទទួលបានប្រាក់អតីតភាពនេះទេ ។
- កម្មករនិយោជិត បានលើកឡើងថា ប្រកាសរបស់ក្រសួងផ្តល់ជូនអត្ថប្រយោជន៍ នៃប្រាក់អតីតភាពការងារ និងប្រាក់ទ្រទ្រង់ជីវភាពនេះ ជូនតែកម្មករកាត់ដេរដែលធ្វើការងារស្រាលៗ ចំណែកពួកគាត់ដែលធ្វើការងារធ្ងន់ៗក៏ត្រូវទទួលបានដូចគ្នាដែរ ។
- ភាគីកម្មករនិយោជិតបញ្ជាក់បន្ថែមថា កម្មករនិយោជិតធ្វើការទាមទារនេះ គឺដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់ថា តើពួកគាត់មានសិទ្ធិទទួលបានប្រាក់អតីតភាពការងារនេះដែរ ឬ អត់ ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា កម្មករនិយោជិតសរុបទាំង ៥០ នាក់នេះ បែងចែកជាបីផ្នែក គឺ ផ្នែកផលិត មានកម្មករនិយោជិតចំនួន ១៩ នាក់ ផ្នែកឃ្លាំង មានកម្មករនិយោជិតចំនួន ០៦នាក់ និងផ្នែកទីផ្សារ មានកម្មករនិយោជិតចំនួន ២៥ នាក់ ។ ហើយពួកគាត់ទាំងនោះ ទទួលបានប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងៗ និងខុសៗគ្នា ។ កម្មករនិយោជិតផ្នែកផលិត និងផ្នែកឃ្លាំង ទទួលបានប្រាក់ឈ្នួលគោលចំនួន ៥០ដុល្លារអាមេរិក ក្នុងមួយខែ ក្នុងនោះក្រុមហ៊ុនបានផ្តល់ប្រាក់លើកទឹកចិត្តបន្ថែមទៀតគឺប្រាក់ទ្រទ្រង់ជីវភាពចំនួន ២០០០០ រៀល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ២០០០០ រៀល ក្នុងមួយខែ ប្រសិនបើកម្មករនិយោជិតនោះមកធ្វើការអត់ឈប់ក្នុងមួយខែនោះ និងទទួលបានប្រាក់ឈ្នួលគោលតែមួយមុខប៉ុណ្ណោះ ។ ដោយឡែកកម្មករនិយោជិត ផ្នែកទីផ្សារវិញ បែងចែកជាពីរក្រុមគឺក្រុមដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូន (ម៉ូតូ ឬ រថយន្ត) ដោយខ្លួនឯង និងក្រុមដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូន (ម៉ូតូ ឬ រថយន្ត) របស់ក្រុមហ៊ុន ហើយក្រុមហ៊ុនមិនបានផ្តល់ជូននូវប្រាក់លើកទឹកចិត្តនេះទេ ព្រោះសំអាងថា ពួកគាត់ទាំងនោះអាចរកកំរៃបានច្រើនជាងកម្មករនិយោជិត ផ្នែកផលិត និងផ្នែកឃ្លាំងតាមរយៈស៊ីភាគរយពីការលក់ ។

ចំពោះការទទួលបានប្រាក់កំរៃលើកទឹកចិត្តរបស់កម្មករនិយោជិតផ្នែកទីផ្សារមានចំនួនខុសគ្នា ទៅតាមចំនួនទឹកផ្លៃឈើដែលពួកគេអាចលក់បាន មានន័យថា លក់បានកាន់តែច្រើន ទទួលបានប្រាក់លើកទឹកចិត្តកាន់តែច្រើន និងខុសគ្នាទៅតាមប្រភេទដែលកម្មករផ្នែកទីផ្សារនោះបានលក់ផលិតផល ។

- ភាគីក្រុមហ៊ុនបានអះអាងថា ខ្លួនមិនអាចផ្តល់ជូនកម្មករនិយោជិតតាមការទាមទារទាំងពីរចំណុចនេះបានទេ ដោយហេតុថា ពុំមានបទបញ្ញត្តិណាមួយនៃច្បាប់ស្តីពីការងារ ឬ វិធានផ្សេងទៀត តម្រូវឱ្យផ្នែកសិប្បកម្មផ្តល់ប្រាក់អតីតភាព ឬ ប្រាក់រង្វាន់លើកទឹកចិត្តដល់កម្មករនិយោជិតរបស់ខ្លួនឡើយ ហើយអ្វីដែលក្រុមហ៊ុនបានអនុវត្តកន្លងមកនោះ គឺមានលក្ខណៈប្រសើរណាស់ទៅហើយ ម្យ៉ាងទៀត ក្រុមហ៊ុនមិនបានលឺថា កម្មករធ្វើការទាមទារដូចខាងសហជីពបានអះអាងទេ គឺខាងសហជីពខ្លួនឯងជាអ្នកចង់ទាមទារតែម្តង ។
- ចំណែកឯភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចលើករណីនេះ ថាតើការងារប្រភេទណាទើបអាចទទួលបានប្រាក់អតីតភាព និងប្រាក់ឧបត្ថមទ្រទ្រង់ជីវភាព ព្រោះថា ពួកគេសព្វថ្ងៃនេះធ្វើការធ្ងន់ៗ ដោយត្រូវលើក លី សែង ទឹកផ្លែឈើជាច្រើន ។
- នៅក្នុងសវនាការ ក្រុមហ៊ុននៅតែប្រកាន់ពីគោលជំហ ដោយមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតពីប្រាក់អតីតភាពការងារ និងប្រាក់ទ្រទ្រង់ជីវភាពបានទេ ដោយហេតុថា ច្បាប់ស្តីពីការងារមិនបានតម្រូវឱ្យសិប្បកម្មត្រូវផ្តល់ជូនទេ ។

**ចំណុចវិវាទទី២ : កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើ ម៉ារី ផ្តល់ប្រាក់ទ្រទ្រង់ជីវភាព ដោយហេតុថា កម្មករនិយោជិតធ្វើការនៅសិប្បកម្ម ក៏ដូចកម្មករនិយោជិតធ្វើការនៅផ្នែកវាយណក័ណ្ឌកាត់ដេរ និងផលិតស្បែកជើងដែរ ដែលទទួលបានអត្ថប្រយោជន៍នេះ**

- ភាគីកម្មករនិយោជិត និងក្រុមហ៊ុនបានឯកភាពថា ចំណុចវិវទទី២ ខុសគ្នាពីការទាមទារចំណុចវិវាទទី១ ខាងលើ គឺដោយហេតុថា ចំណុចទាមទារទី១ គឺទាក់ទងនឹងប្រាក់រង្វាន់អតីតភាពការងារ ហើយចំណុចនៃការទាមទារទី២ គឺទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ទ្រទ្រង់ជីវិភាព ។
- ចំណែកឯអង្គហេតុនៃចំណុចទាមទារទី២នេះ គឺដូចគ្នានឹងចំណុចទាមទារវិវាទទី១ ដូចបានរៀបរាប់ខាងលើ ។

## ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងសំណុំរឿងនេះ សហជីពខ្មែរប្រចាំសិប្បកម្ម ម៉ារី ដែលជាតំណាងកម្មករនិយោជិតបានធ្វើការទាមទារឱ្យកម្មករនិយោជិតនៅសិប្បកម្ម ម៉ារី ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើកម្មករនិយោជិតទាំងនោះត្រូវទទួលបានប្រាក់រង្វាន់អតីភាពការងារ និងប្រាក់ឧបត្ថម្ភទ្រទ្រង់ជិវភាពដែរ ឬ ទេ ?



Khea

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារចែងថា *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនេះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំនិងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីសុំចុះបញ្ជិកា ។...*

*ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថា បានចុះបញ្ជិការួចហើយ ។..."*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ ខាងលើនេះ មានន័យថា អង្គការងារវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈនោះទទួលបានការចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យការងារ ។

លើសពីនេះទៀត ប្រការ ៥ នៃប្រកាស ៣០៥ កថាខ័ណ្ឌ១ ចែងថា *" សហជីពទាំងអស់ដែលបានបង្កើតឡើងនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ស្របតាមមាត្រា២៦៨ នៃច្បាប់ស្តីពីការងារ មានសិទ្ធិតំណាងឱ្យផលប្រយោជន៍របស់សមាជិករបស់ខ្លួន តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការងារ ។"*

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពខ្មែរបានទទួលបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧។ ហេតុដូច្នេះហើយ សហជីពនេះមានសិទ្ធិ និងផលប្រយោជន៍ដែលទទួលស្គាល់ដោយច្បាប់ស្តីពីការងារ ហើយគាត់មានសិទ្ធិក្នុងការតំណាងឱ្យកម្មករដែលជាសមាជិករបស់ខ្លួន ដូចដែលមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារ និងមាត្រា ៥ កថាខ័ណ្ឌ ១ នៃប្រកាសលេខ ៣០៥ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា ដោះស្រាយវិវាទសំណុំរឿងនេះ ចំពោះតែកម្មករនិយោជិតដែលជាសមាជិកសហជីពខ្មែរប្រចាំសិប្បកម្ម ម៉ារី ប៉ុណ្ណោះ ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើ ម៉ារី ផ្តល់ប្រាក់អតីតភាពការងារ ដោយហេតុថា កម្មករនិយោជិតធ្វើការនៅសិប្បកម្ម ក៏ដូចកម្មករនិយោជិតធ្វើការ នៅផ្នែកវាយណភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើងដែរ ហើយដែលត្រូវទទួលបានអត្ថប្រយោជន៍ដូចគ្នា**

ក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើ ម៉ារី ផ្តល់ប្រាក់រង្វាន់អតីតភាពការងារដល់កម្មករនិយោជិតធ្វើការងារចាប់ពីមួយឆ្នាំឡើងទៅ ទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន០២ ដុល្លារអាមេរិកក្នុងមួយខែ និងបន្ថែមចំនួន ០១ ដុល្លារអាមេរិកបន្តទៀត តាមចំនួនឆ្នាំតរៀងមករហូតដល់ឆ្នាំទី៤ ទទួលបានប្រាក់រង្វាន់អតីតភាព ចំនួន ០៥ ដុល្លារអាមេរិក ក្នុងមួយខែ ដោយសារពួកគាត់ ក៏ជាកម្មករនិយោជិត ដូចកម្មករនិយោជិតនៅផ្នែកវាយណភ័ណ្ឌ តម្បាញ ដេរស្បែងជើងដែរ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើកម្មករនិយោជិតធ្វើការនៅសិប្បកម្មទឹកផ្លែឈើ ម៉ារី មានសិទ្ធិទទួលបានប្រាក់អតីតភាពការងារនេះ ដែរ ឬ ទេ ?

ចំណុចទី៥ នៃសេចក្តីជូនដំណឹងលេខ ០១៧ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចែងថា "*កម្មករនិយោជិត ដែលធ្វើការបានយូរនៅក្នុងរោងចក្រ ឬ សហគ្រាសណាមួយ ត្រូវបានប្រាក់រង្វាន់ការងារដូចតទៅ :-*

*៥.១-ធ្វើការចាប់ពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន ២ ដុល្លារអាមេរិកក្នុងមួយខែ។*

*៥.២-ធ្វើការចាប់ពី២ឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន ៣ ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺ ០២ ដុល្លារអាមេរិកនៃឆ្នាំទី១ បូកនឹង ០១ ដុល្លារនៃឆ្នាំទី២។*

*៥.៣-ធ្វើការចាប់ពី៣ឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន ៤ ដុល្លារអាមេរិកក្នុងមួយខែ ពោល គឺ ០២ដុល្លារអាមេរិកនៃឆ្នាំទី១ បូកនឹង ០១ដុល្លារអាមេរិកនៃឆ្នាំទី២ បូកនឹង ០១ដុល្លារអាមេរិកនៃឆ្នាំទី៣។*

*៥.៤-ធ្វើការចាប់ពី៤ឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន ៤ ដុល្លារអាមេរិកក្នុងមួយខែ ពោល គឺ ០២ ដុល្លារអាមេរិកនៃឆ្នាំទី១ បូកនឹង០១ ដុល្លារអាមេរិកនៃឆ្នាំទី២ បូកនឹង០១ដុល្លារអាមេរិកនៃឆ្នាំទី៣ បូកនឹង ០១ដុល្លារអាមេរិកនៃឆ្នាំទី៤។"...*

សេចក្តីជូនដំណឹងលេខ ០១៧ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខាងលើ សំរាប់ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

តាមខ្លឹមសារនៃសេចក្តីជូនដំណឹងខាងលើ មានន័យថា ប្រាក់រង្វាន់អតីតភាពការងារនេះ គឺសំដៅទៅលើការផ្តល់ជូនកម្មករនិយោជិតដែលបំរើការងារនៅផ្នែកវាយណភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើង គឺមិនសំដៅទៅលើការផ្តល់ជូនកម្មករនិយោជិតដែលបំរើការងារនៅផ្នែកផ្សេងៗទៀត ដូចជា ផ្នែកសិប្បកម្មទឹកផ្លែឈើ ម៉ារី ទេ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាអ្នកចេញប្រកាសក្នុងការកំណត់ថា តើកម្មករនិយោជិតបំរើការងារនៅផ្នែកណាខ្លះ នឹងទទួលបានប្រាក់រង្វាន់អតីតភាពការងារនេះ។ ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ទាក់ទងនឹងការទាមទារនេះ មិនមានបទបញ្ញត្តិស្តីពីការងារ កិច្ចសន្យាការងារ បទបញ្ជាផ្ទៃក្នុង ឬ អនុសញ្ញារួមណាមួយ ចែងពីការផ្តល់ប្រាក់រង្វាន់អតីភាពការងារនេះ ជូនដល់កម្មករនិយោជិតផ្នែកសិប្បកម្មទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានមូលដ្ឋានច្បាប់នៅក្នុងការទាមទារទាក់ទងនឹងចំណុចនេះទេ។ ការទាមទាររបស់កម្មករនិយោជិត មានលក្ខណៈលើសអ្វីដែលច្បាប់ផ្តល់ឱ្យ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតលើចំណុចវិវាទនេះ ជាវិវាទផលប្រយោជន៍ ( សូមមើលសេចក្តីបង្គាប់លេខ ១៣៨/០៨- ឈេហ្សុិន.ចំណុចវិវាទទី៣)។

កន្លងមក ទាក់ទងនឹងវិវាទផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាអំពីភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីនៃវិវាទ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះផ្តល់អំណាចផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុនមួយ និងសិទ្ធិស្របច្បាប់ក្នុងការនាំ

សំណុំរឿងវិវាទអំពីប្រយោជន៍មួយមកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។ ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា *សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ* ។

ម៉្យាងវិញទៀត ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា *"សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយដើម្បីជំនួសសេចក្តីបង្គាប់នេះ ។"*

ប្រសិនបើសហជីពមួយ មិនទាន់មានភាពជាតំណាងបំផុតទេ នាំឱ្យសហជីពនេះមិនមានសិទ្ធិស្របច្បាប់ក្នុងការធ្វើអនុសញ្ញារួមក្នុងនាមកម្មករក្នុងរោងចក្រទាំងមូលទេ (សូមមើលមាត្រា ៩៦ កថាខ័ណ្ឌទី២-ខ និងប្រកាសលេខ ៣០៥ ប្រការ ៩ កថាខណ្ឌទី ១)។ សិទ្ធិនេះជារបស់សហជីព ដែលបានចុះបញ្ជិកា និងមានសមាជិកច្រើនជាងគេ ហើយបំពេញបានតាមលក្ខណៈវិនិច្ឆ័យឯទៀតដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បដិសេធពិចារណាវិវាទអំពីប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះ ជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ។ *(សូមមើលសេចក្តីបង្គាប់លេខ ១០១/០៨ -ជីឌីអឹម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ )* ។

យោងតាមអង្គហេតុ និងភស្តុតាង សហជីពនេះបានចុះបញ្ជិកាត្រឹមត្រូវ និងមានសហជីពចំនួន ១៩ នាក់ ក្នុងចំណោមកម្មករនិយោជិតជាង ៥០ នាក់ ហើយសហជីពមិនទាន់មានភាពជាតំណាងបំផុតនៅឡើយទេ។

ហេតុនេះ ផ្អែកលើការបកស្រាយខាងលើ នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើវិវាទផលប្រយោជន៍ ពេលនោះភាគីនឹងមិនអាចធ្វើកូដកម្ម ឬ ឡុកអៅ ឬ នាំយកវិវាទអំពីប្រយោជន៍ផ្សេងទៀតមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាលជាថ្មីម្តងទៀតក្នុងអំឡុងពេលមួយឆ្នាំ។

យោងតាមការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពខ្មែរប្រចាំសិប្បកម្មផលិតទឹកផ្លែឈើម៉ារី មិនទាន់មានសិទ្ធិស្របច្បាប់ក្នុងការនាំយកវិវាទទាក់ទងនឹងផលប្រយោជន៍ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនពិចារណាចំពោះការទាមទារនេះ។

**ចំណុចវិវាទទី២ : កម្មករនិយោជិតទាមទារឱ្យសិប្បកម្មទឹកផ្លែឈើ ម៉ារី ផ្តល់ប្រាក់ទ្រទ្រង់ជីវភាព ដោយហេតុថា កម្មករនិយោជិតធ្វើការនៅសិប្បកម្ម ក៏ដូចកម្មករនិយោជិតធ្វើការនៅផ្នែកវាយណភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែរ ដែលទទួលបានអត្ថប្រយោជន៍នេះ**

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/ស.ជ.ណ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ ចែងថា *"ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត ជាកូនជាង អ្នកធ្វើការម្តងម្កាល ឬ អណ្តែត*

*អ្នកសាកល្បង និងអ្នកពេញសិទ្ធិ ដែលធ្វើការនៅរោងចក្រ សបាគ្រាស គ្រឹះស្ថានផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងក្នុងម្នាក់ៗចំនួន ៦ (ប្រាំមួយ) ដុល្លារសហរដ្ឋអាមេរិកក្នុង១ខែ។ ប្រាក់ឧបត្ថម្ភនេះ មិនត្រូវបានបូកបញ្ចូលធ្វើជាប្រាក់ឈ្នួលសុទ្ធសាធទេ (ប្រាក់ឈ្នួលគោល) ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមខ្លឹមសារនៃសេចក្តីជូនដំណឹងខាងលើនេះ បានចែងយ៉ាងច្បាស់លាស់ថា ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត គឺធ្វើឡើងសំរាប់តែកម្មករនិយោជិតដែលធ្វើការនៅរោងចក្រសបាគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងតែប៉ុណ្ណោះ គឺមិនគ្របដណ្តប់ទៅលើកម្មករនិយោជិតដែលបំរើការងារនៅផ្នែកផ្សេងៗទៀត ដូចជា ផ្នែកសិប្បកម្មទឹកផ្លែឈើម៉ារី នេះទេ។ម្យ៉ាងទៀត នៅក្នុងកិច្ចសន្យាការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន ក៏ដូចជាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនគ្មានបញ្ញត្តិណាមួយបានចែងអំពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពនេះដែរ។ ចំណែកឯអនុសញ្ញារួមរវាងភាគីទាំងពីរក៏ពុំទាន់មានដែរ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទាក់ទងនឹងការទាមទាររបស់កម្មករនិយោជិតរបស់សិប្បកម្មទឹកផ្លែឈើម៉ារី មិនមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ឡើយ ដែលធ្វើឱ្យការទាមទារនេះមានលក្ខណៈជាការទាមទារពាក់ព័ន្ធនឹងផលប្រយោជន៍ ព្រោះការទាមទារនេះមានលក្ខណៈលើសពីអ្វីដែលច្បាប់ផ្តល់ឱ្យ ដូចគ្នានឹងការទាមទារចំណុចវិវាទទី១ដែរ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:** មិនពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យសិប្បកម្មទឹកផ្លែឈើម៉ារី ផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ។

**ចំណុចវិវាទទី២:** មិនពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យសិប្បកម្មទឹកផ្លែឈើម៉ារី ផ្តល់ប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាព ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេង ទូចហ៊ុន**

ហត្ថលេខា: -----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: -----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈយា**

ហត្ថលេខា: -----------------------------------